ខេមបូឌា ស៊ីឃ្យូរីធី
柬埔寨证券
CAMBODIA SECURITIES

Picasso
CITY GARDEN

# សេចក្តីជូនដំណឹង
## ស្តីពីការធ្វើបរិវិសកម្មមូលបត្រកម្មសិទ្ធិដែលបោះផ្សាយលក់លើកដំបូងជាសាធារណៈរបស់
## ក្រុមហ៊ុន ពីកាសូ ស៊ីធី ហ្គាដិន ឌីវេឡុបមិុន ម.ក

**ក្រុមហ៊ុន ពីកាសូ ស៊ីធី ហ្គាដិន ឌីវេឡុបមិុន ម.ក** (តទៅនេះហៅកាត់ថា "**ក្រុមហ៊ុន**" ឬ "**ពីកាសូ**") ដែលជាក្រុមហ៊ុនអភិវឌ្ឍអចលនទ្រព្យធំមួយក្នុងចំណោមក្រុមហ៊ុនអភិវឌ្ឍអចលនទ្រព្យឈានមុខគេនៅព្រះរាជាណាចក្រកម្ពុជា មានកិត្តិយសសូមជម្រាបជូនដំណឹងដល់សាធារណៈជនមេត្តាជ្រាបថា៖ ក្រុមហ៊ុនយើងខ្ញុំបានទទួលការអនុញ្ញាត និងចុះបញ្ជីជាស្ថាពរពី **និយ័តករមូលបត្រកម្ពុជា** ("**ន.ម.ក**") លើឯកសារផ្តល់ព័ត៌មានសម្រាប់ការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិលើកដំបូងជាសាធារណៈ (តទៅនេះហៅកាត់ថា "**ការបោះផ្សាយ**") (តាមរយៈសេចក្តីសម្រេចលេខ២១៧/២៥ ន.ម.ក/ស.ស.រ. ចុះថ្ងៃទី ០៣ ខែតុលា ឆ្នាំ២០២៥។ អាស្រ័យហេតុនេះ ដោយមានជំនួយពី **ក្រុមហ៊ុន ខេមបូឌា ស៊ីឃ្យូរីធី ម.ក** ជាទីប្រឹក្សាហិរញ្ញវត្ថុ និងជាក្រុមហ៊ុនធានាទិញមូលបត្រ ក្រុមហ៊ុនសូមអញ្ជើញវិនិយោគិន ដែលមានបំណងស្នើសុំធ្វើបរិវិសកម្ម អញ្ជើញមកដាក់ពាក្យស្នើសុំចូលរួមធ្វើបរិវិសកម្មនៃសំណើលក់មូលបត្រកម្មសិទ្ធិលើកដំបូងជាសាធារណៈ។

## ១. ព័ត៌មានសង្ខេបអំពីការបោះផ្សាយ

- ប្រភេទមូលបត្រកម្មសិទ្ធិដែលបោះផ្សាយលក់៖ មូលបត្រកម្មសិទ្ធិមានសិទ្ធិបោះឆ្នោត
- ចំនួនមូលបត្រកម្មសិទ្ធិសរុបដែលបោះផ្សាយលក់៖ ១០.០០០.០០០ ភាគហ៊ុន
- ថ្លៃលក់ក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ៖ ៤.៨០០ រៀល (១,២០ ដុល្លារអាមេរិក)
- ទំហំទឹកប្រាក់ទទួលបានពីការបោះផ្សាយសរុប៖ ៤៨.០០០.០០០.០០០ (ប្រមាណ ១២.០០០.០០០ ដុល្លារអាមេរិក)
- ចំនួនមូលបត្រអប្បបរមាសម្រាប់ការធ្វើបរិវិសកម្ម៖ ១០០ ភាគហ៊ុន

## ២. ការធ្វើបរិវិសកម្ម

ក. **រយៈពេលធ្វើបរិវិសកម្ម៖** ចាប់ពីថ្ងៃទី១៣ ដល់ ថ្ងៃទី២៤ ខែតុលា ឆ្នាំ២០២៥ (ថ្ងៃធ្វើការនៅព្រះរាជាណាចក្រកម្ពុជា)
- ពេលព្រឹក៖ ចាប់ពីម៉ោង ០៨:០០ ដល់ម៉ោង ១២:០០ ថ្ងៃត្រង់
- ពេលថ្ងៃ៖ ចាប់ពីម៉ោង ១៣:០០ ដល់ម៉ោង ១៧:០០

ខ. **កាលបរិច្ឆេទបែងចែកមូលបត្រកម្មសិទ្ធិ៖** ថ្ងៃទី៣ ខែវិច្ឆិកា ឆ្នាំ២០២៥

ព្រះរាជាណាចក្រកម្ពុជា ក្រុមហ៊ុន ខេមបូឌា ស៊ីឃ្យូរីធី ម.ក CAMBODIA SECURITIES PLC. KINGDOM OF CAMBODIA

**គ. ឯកសារផ្តល់ព័ត៌មាន និងពាក្យស្នើសុំធ្វើបរិវិសកម្ម អាចទាញយកបានតាមរយៈ**

| ឯកសារផ្តល់ព័ត៌មាន និងពាក្យស្នើសុំធ្វើបរិវិសកម្ម | |
|---|---|
| **Soft Copy by:**<br>https://shorturl.at/DEvQu<br>ឬ ស្កេនដើម្បីទទួលបានឯកសារ | **Hard copy by:**<br>**ក្រុមហ៊ុន ខេមបូឌា ស៊ីឃ្យូរីធី ម.ក**<br>ជាន់ទី ២៩ បន្ទប់លេខ ២៩០២ នៃអគារលេខ ៤១ ផ្លូវលេខ ៣៦០ ភូមិ ៧ សង្កាត់ទួលស្វាយព្រៃទី១ ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា<br>ទូរសព្ទ៖ (៨៥៥) ២៣ ៩៩៧ ៨៨៨ |

**ឃ. ទីកន្លែងធ្វើបរិវិសកម្ម (សម្រាប់ទទួលបានឯកសារផ្តល់ព័ត៌មាន និងពាក្យស្នើសុំធ្វើបរិវិសកម្ម)៖**

| ល.រ | ឈ្មោះក្រុមហ៊ុន | គេហទំព័រ | ទូរសព្ទលេខ |
|---|---|---|---|
| ១ | ក្រុមហ៊ុន ខេមបូឌា ស៊ីឃ្យូរីធី ម.ក | www.cambodiasecurities.com.kh | +(៨៥៥) ២៣ ៩៩៧ ៨៨៨ |
| ២ | ក្រុមហ៊ុនមូលបត្រ ភីភី លីង ឯ.ក | www.pplinksecurities.com.kh | +(៨៥៥) ២៣ ៨៦៦ ៦២២ |

**ង. លក្ខខណ្ឌចូលរួម**

១. វិនិយោគិនត្រូវមានលេខអត្តសញ្ញាណវិនិយោគិន (Investor Identification) ដែលមានសុពលភាព ដែលចេញដោយ ន.ម.ក។

២. វិនិយោគិនត្រូវមានលេខគណនីជួញដូរមូលបត្រ (Securities Trading Account) នៅក្រុមហ៊ុនមូលបត្រ ដែលបានទទួលអាជ្ញាបណ្ណពី ន.ម.ក។

៣. វិនិយោគិនត្រូវដាក់ពាក្យស្នើសុំចូលរួមធ្វើបរិវិសកម្មទៅកាន់ទីតាំងដូចបានបញ្ជាក់ខាងលើ និងដាក់ប្រាក់ចំនួន ១០០% នៃថ្លៃទិញមូលបត្រកម្មសិទ្ធិសរុប។

ព្រះរាជាណាចក្រកម្ពុជា ក្រុមហ៊ុន ខេមបូឌា ស៊ីឃ្យូរីធី ម.ក CAMBODIA SECURITIES PLC KINGDOM OF CAMBODIA

## ច. ការផ្ទេរប្រាក់

១. វិនិយោគិន ត្រូវដាក់ប្រាក់ទៅក្នុងគណនីបរិវិសកម្មរបស់ ក្រុមហ៊ុន ពីកាសូ ស៊ីធី ហ្គាជិន ឌីវេឡុបមិន ម.ក

| | |
|---|---|
| ឈ្មោះគណនី | **ពីកាសូ ស៊ីធី ហ្គាជិន ឌីវេឡុបមិន ម.ក-គណនីបរិវិសកម្ម** |
| លេខគណនី(ប្រាក់រៀល) | 00010583966617 |
| លេខគណនី(ប្រាក់ដុល្លារអាមេរិក) | 00010583966616 |
| លេខកូដ SWIFT | ACLBKHPP |
| កំណត់សម្គាល់ក្នុងការស្នើសុំទិញ | "ឈ្មោះវិនិយោគិន" និង "លេខគណនីជួញដូរ"<br>ឧទាហរណ៍៖ លី ស៊ីង ០០១០១១ |
| គោលបំណងក្នុងការដាក់/ផ្ទេរប្រាក់ (ប្រសិនបើចាំបាច់) | "ការធ្វើបរិវិសកម្មសម្រាប់ PCG IPO" |

២. វិនិយោគិនត្រូវដាក់ជូនពាក្យស្នើសុំធ្វើបរិវិសកម្មដែលបានបំពេញរួច ដោយមានភ្ជាប់ជាមួយបង្កាន់ដៃដាក់ប្រាក់/ផ្ទេរប្រាក់ ទៅក្រុមហ៊ុន ខេមបូឌា ស៊ីឃ្យួរីធី ម.ក (នៅអំឡុងថ្ងៃ និងម៉ោងធ្វើការ ក្នុងរយៈពេលធ្វើបរិវិសកម្ម)។

៣. រាល់ការដាក់ប្រាក់ រួមទាំងការផ្ទេរប្រាក់ពីក្រៅប្រទេស ត្រូវដាក់ចូលគណនីបរិវិសកម្មអោយបានមុនម៉ោង ៥:០០ ល្ងាច (ម៉ោងនៅព្រះរាជាណាចក្រកម្ពុជា) នៅថ្ងៃចុងក្រោយនៃថ្ងៃបរិវិសកម្ម។

៤. វិនិយោគិនដែលបានដាក់ពាក្យស្នើសុំធ្វើបរិវិសកម្ម និងបានបង់ប្រាក់រួចរាល់សម្រាប់ការធ្វើបរិវិសកម្ម មិនអាចលុបចោលការធ្វើបរិវិសកម្ម ឬស្នើសុំការបង្វិលប្រាក់ដែលទូទាត់លើការធ្វើបរិវិសកម្មត្រឡប់ទៅវិញបានឡើយ។

៥. វិនិយោគិនមិនទទួលបានការប្រាក់ ឬប្រាក់សំណងនានា ក្នុងអំឡុងពេលធ្វើបរិវិសកម្មនៃមូលបត្រកម្មសិទ្ធិឡើយ។

ព្រះរាជាណាចក្រកម្ពុជា ក្រុមហ៊ុន ខេមបូឌា ស៊ីឃ្យួរីធី ម.ក CAMBODIA SECURITIES PLC. KINGDOM OF CAMBODIA

## ៣. ការប្រកាសអំពីលទ្ធផលនៃការធ្វើបរិវិសកម្ម

ក្រុមហ៊ុន ពីកាសូ ស៊ីធី ហ្គាដិន ឌីវេឡុបមិន ម.ក ជាមួយនឹង ក្រុមហ៊ុន ខេមបូឌា ស៊ីឃ្យួរីធី ម.ក នឹងប្រកាសលទ្ធផលនៃការធ្វើបរិវិសកម្ម ទៅកាន់វិនិយោគិនក្រោយពីការធ្វើបរិវិសកម្មបានបញ្ចប់។

១. លទ្ធផលនៃការធ្វើបរិវិសកម្ម នឹងត្រូវបានប្រកាសជាសាធារណៈតាមរយៈសារព័ត៌មានដែលទទួលស្គាល់ដោយ ន.ម.ក គេហទំព័រ និងបណ្តាញសង្គមផ្លូវការនានា ដូចជារបស់ក្រុមហ៊ុនជានាទិញ និងក្រុមហ៊ុនបោះផ្សាយផ្សាយ។

២. ការបែងចែកមូលបត្រកម្មសិទ្ធិទៅឱ្យវិនិយោគិន គឺស្ថិតក្រោមការសម្រេចរបស់ក្រុមហ៊ុន ពីកាសូ ស៊ីធី ហ្គាដិន ឌីវេឡុបមិន ម.ក និងក្រុមហ៊ុន ខេមបូឌា ស៊ីឃ្យួរីធី ម.ក ។

៣. ក្រុមហ៊ុនជានាទិញមូលបត្រ មានសិទ្ធិធ្វើមោឃភាព ឬលុបចោលការធ្វើបរិវិសកម្មលើមូលបត្រកម្មសិទ្ធិពីសំណាក់វិនិយោគិនណាដែលខកខានមិនបានគោរពតាមនីតិវិធី។

**សម្រាប់ព័ត៌មានបន្ថែមអំពីការធ្វើបរិវិសកម្ម សូមទំនាក់ទំនង៖**

| ល.រ | ឈ្មោះក្រុមហ៊ុន | បុគ្គលសម្រាប់ទំនាក់ទំនង | តួនាទី | អ៊ីម៉ែល | លេខទំនាក់ទំនង |
|---|---|---|---|---|---|
| ១. | ខេមបូឌា ស៊ីឃ្យួរីធី ម.ក | លោកស្រី Teng, Ying-Shan | ប្រធានភ្នាក់ងារក្រុមហ៊ុនមូលបត្រ | chloe.teng@cambodiasecurities.com.kh | (855) 23 997 888 |
| ២. | ខេមបូឌា ស៊ីឃ្យួរីធី ម.ក | កញ្ញា ឡុង សុខនីន | ភ្នាក់ងារក្រុមហ៊ុនមូលបត្រ | soknin.long@cambodiasecurities.com.kh | (855) 89 545 698 |
| ៣. | ខេមបូឌា ស៊ីឃ្យួរីធី ម.ក | កញ្ញា ជ្រិន ទិត្យធីតា | ភ្នាក់ងារក្រុមហ៊ុនមូលបត្រ | tiththida.chrin@cambodiasecurities.com.kh | (855) 96 969 1911 |
| ៤. | ខេមបូឌា ស៊ីឃ្យួរីធី ម.ក | កញ្ញា ម៉ែន ចាន់សុផល | ភ្នាក់ងារក្រុមហ៊ុនមូលបត្រ | chansophal.men@cambodiasecurities.com.kh | (855) 96 725 5258 |


***សេចក្តីថ្លែងការណ៍៖***

*គោលការណ៍ណែនាំស្តីពីការធ្វើបរិវិសកម្មនេះត្រូវបានរៀបចំ និងផ្តល់ជូនសម្រាប់គោលបំណងផ្តល់ព័ត៌មានតែប៉ុណ្ណោះ ហើយមិនគួរត្រូវបានរៀបចំឡើងវិញទាំងស្រុង ឬមួយផ្នែក និងផ្តល់ជូនអ្នកដទៃ ឬផ្សព្វផ្សាយជាសាធារណៈ ហើយមិនគួរត្រូវបានបកស្រាយថា ជាការអញ្ជើញ ការផ្តល់ដំបូន្មាន ឬការជានាក្នុងការទិញមូលបត្រកម្មសិទ្ធិណាមួយឡើយ។ វិនិយោគិនត្រូវបានលើកទឹកចិត្ត និងណែនាំឱ្យអានដោយប្រុងប្រយ័ត្ន និងយល់ច្បាស់អំពីឯកសារព័ត៌មានស្តីពីការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិលើកដំបូងជាសាធារណៈរបស់ ក្រុមហ៊ុន ពីកាសូ ស៊ីធី ហ្គាដិន ឌីវេឡុបមិន ម.ក ជាពិសេស ព័ត៌មានស្តីពីហានិភ័យ និងព័ត៌មានហិរញ្ញវត្ថុរបស់ក្រុមហ៊ុន។ អ្នកទទួលគោលការណ៍ណែនាំនេះ គួរតែផ្អែកលើការសម្រេចចិត្តឯករាជ្យរបស់ខ្លួន ទាក់ទងនឹងការទិញមូលបត្រទាំងនេះ។ យើងខ្ញុំនឹងមិនទទួលខុសត្រូវចំពោះការខូចខាតណាមួយ ដែលកើតឡើងពីការប្រើប្រាស់គោលការណ៍ណែនាំនេះទោះក្នុងទម្រង់ណាមួយឡើយ។*


ព្រះរាជាណាចក្រកម្ពុជា
ក្រុមហ៊ុន
ខេមបូឌា ស៊ីឃ្យួរីធី ម.ក
CAMBODIA SECURITIES PLC.
KINGDOM OF CAMBODIA